# សេចក្តីជូនដំណឹង
# ស្តីពី
# វិធានការក្នុងអំឡុងពេលលើកការឈប់សម្រាកបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២០

យោងអនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០ ស្តីពីការលើកការឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ នៅថ្ងៃទី១៣ ទី១៤ ទី១៥ និងទី១៦ ខែមេសា ឆ្នាំ២០២០, ប្រកាសលេខ០១២/២០ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០ ស្តីពីការលើកពេលថ្ងៃឈប់សម្រាកក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២០ និងការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបញ្ជាក់បន្ថែមដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តន៍នៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២០នេះ កម្មករនិយោជិតត្រូវបន្តធ្វើការដូចថ្ងៃធម្មតានៅតាមសហគ្រាស គ្រឹះស្ថានរបស់ខ្លួន។ ករណីកម្មករនិយោជិតឈប់សម្រាកក្នុងអំឡុងពេលនេះ កម្មករនិយោជិតត្រូវធ្វើចត្តាឡីស័កនៅផ្ទះរបស់ខ្លួនក្នុងរយៈពេល ១៤ថ្ងៃ មុនចូលបំពេញការងារវិញ។

ប្រសិនបើនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកក្នុងអំឡុងពេលនេះ និយោជកត្រូវទទួលបន្ទុកចេញប្រាក់ឈ្នួលដល់កម្មករនិយោជិតដែលមិនបានបំពេញការងារ ដោយមូលហេតុធ្វើចត្តាឡីស័កសម្រាប់រយៈពេល ១៤ថ្ងៃ។ ក្នុងករណីកម្មករនិយោជិតឈប់សម្រាកដោយឯកឯង ដោយមិនមានការអនុញ្ញាតពីនិយោជក កម្មករនិយោជិតមិនត្រូវទទួលបានប្រាក់ឈ្នួលក្នុងរយៈពេលធ្វើចត្តាឡីស័កនេះឡើយ។

អាស្រ័យហេតុនេះ សូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ទាំងអស់គ្នា។

ក្រសួងមានសេចក្តីជឿជាក់ថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

*ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*

*រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០*

**រដ្ឋមន្ត្រី**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- អង្គការវិជ្ជាជីវៈគ្រប់លំដាប់ថ្នាក់
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ កាលប្បវត្តិ